កាលបរិច្ឆេទ: ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៨

# មេរៀនដំណាំស្ពៃខៀវ

## បច្ចេកទេសនៃការដាំដំណាំស្ពៃខៀវ

### ១.ការរៀបចំដី

- ភ្ជួរដីហាលដីរយៈពេលពី១០-១៥ថ្ងៃ
- ត្រូវភ្ជួរប្រែដីឱ្យបាន២ទៅ៣ដងថែមទៀតក្នុងជម្រៅដីពី២តឹកទៅ៣តឹក។

### ២.ការលើករង

- ☺ យើងធ្វើរងទទឹងយកប្រវែង១ម៉ែត្រ បណ្ដោយតាមលទ្ធភាព
- ☺ លើកកំពស់រងពី២០ទៅ២៥សង់ទីម៉ែត្រ សម្រាប់រដូវប្រាំង
- ☺ លើកកំពស់រងពី២៥ទៅ៣០សង់ទីម៉ែត្រ សម្រាប់រដូវវស្សា។

### ៣.ការដាំដុះ

- ជាដំបូងយកគ្រាប់ពូជមកហាលថ្ងៃរយៈពេលពី៣០ទៅ៤០នាទី បន្ទាប់មកយកវាមកត្រាំទឹករយៈពេល៣ទៅ៥ម៉ោង រួចហើយផ្អាប់១យប់។

រៀបចំដោយ  លោក យុគ សឿង នាយករងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)

- ត្រូវរៀបចំដីថ្នាលឱ្យបានស្អាត រួចយកខ្សាច់៤ភាគច្របល់ជាមួយគ្រាប់ពូជឱ្យសព្វ ហើយសាបឬព្រោះវានៅលើថ្នាលនោះឱ្យបានស្មើដៃល្អ។
- រោយអំពុកចំបើងទៅលើថ្នាល រួចស្រោចទឹកភ្លាម បន្ទាប់មកធ្វើដំបូលគ្របផង។
- នៅពេលកូនស្ទែមានអាយុ១៥ថ្ងៃ ឬមានចេញសន្លឹក៣ទៅ៤សន្លឹកយើងអាចដកវាទៅស្ទូងបាន។
- ត្រូវផ្អាកស្រោចទឹករយៈពេល១ថ្ងៃមុនដកកូនស្ទែទៅស្ទូង។
- នៅថ្ងៃបន្ទាប់ត្រូវស្រោចទឹកកូនស្ទែរួចហើយដកវាភ្លាម។
- ពីគុម្ពមួយទៅគុម្ពមួយត្រូវទុកគម្លាតពីគ្នាប្រវែង១៥ទៅ២០សង់ទីម៉ែត្រ (ជាមធ្យម១៦ទៅ២០ដើមក្នុង១ម៉ែត្រការ៉េ)។
- ចន្លោះរងឬផ្លូវដើរទុកប្រវែងពី៣០ទៅ៤០សង់ទីម៉ែត្រ(៣-៤តឹក)។

**<u>របៀបម៉្យាងទៀត៖</u>**

- សម្រាប់ការព្រោះផ្ទាល់ៈ បន្ទាប់ពីផ្ទាប់ពូជរួចត្រូវយកវាទៅព្រោះលើរងតែម្តង រួចហើយរោយអំពុកចំបើងពីលើ បន្ទាប់មកស្រោចទឹក៣ដងក្នុង១ថ្ងៃ បើស្ថានភាពដីមានសភាពស្ងួត។
- បើកូនស្ទែដុះមកក្រាស់ពេកត្រូវដកចេញខ្លះ ឬដកវាយកទៅស្ទូងនៅកន្លែងទំនេរ។

## ៤.ការថែទាំ

- ក្រោយពីស្ទូងបានរយៈពេល១០ថ្ងៃ ត្រូវបោចស្មៅ ជ្រុំជើង និងដាក់ជីបំប៉ន (ជីធម្មជាតិ)។
- មើលសត្វល្អិតជាប្រចាំ
- ស្រោចទឹកឱ្យបានគ្រប់គ្រាន់
- បើឃើញកូនស្ពៃណា ចាប់ផ្តើមពណ៌លឿងស្រពោន ត្រូវដកវាចេញហើយយកទៅចោលឱ្យឆ្ងាយ ឬកប់ដីក៏បាន។

## ៥.ការប្រមូលផល

- ផ្អាកស្រោចទឹករយៈពេល១ថ្ងៃមុនពេលប្រមូលផលស្ពៃ
- នៅពេលស្ពៃមានអាយុ៤៥ទៅ៥០ថ្ងៃ យើងអាចប្រមូលផលបានចំពោះស្ពៃសាបគ្រាប់ផ្ទាល់។
- នៅពេលស្ពៃអាយុ៥០ទៅ៦០ថ្ងៃ យើងអាចប្រមូលផលបានចំពោះស្ពៃស្ទូងកូន។
- ទិន្នផលជាមធ្យមទទួលបានពី១៦ទៅ១៨តោនសម្រាប់ផ្ទៃដីដាំ១ហិចតា៕

**សូមអរគុណ**

កាលបរិច្ឆេទៈ ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៨

# មេរៀនដំណាំល្ពៅ

## បច្ចេកទេសនៃការដាំដំណាំល្ពៅ

### ១.ការជ្រើសរើសពូជ

- ពូជបង្កាត់ៈ ជាពូជមានផ្លែច្រើន
- ពូជធម្មតាៈ ជាពូជអាចទុកដាំបន្តបាន
- ពូជដំណាំល្ពៅមានច្រើនប្រភេទដូចជា ល្ពៅក្អែក ល្ពៅភ្នំ ល្ពៅទ្រូ ល្ពៅហាប។ល។

### ២.ការរៀបចំដី

- ភ្ជួរដីហាលដីរយៈពេលពី១០-១៥ថ្ងៃ
- ត្រូវភ្ជួររាស់ប្រែដីឱ្យបាន២ទៅ៣ដងរួចរាស់បំបែកដីឱ្យបានម៉ដ្ឋល្អ។

### ៣.ការរៀបចំរងឬរណ្តៅ

☺ ការលើករងទទឹងគេអាចធ្វើបានចាប់ពី២ទៅ៣ម៉ែត្រដោយភ្ជួរពូនតែម្តង រីឯបណ្តោយរងតាមលទ្ធភាពដី។

រៀបចំដោយ លោក យុគ សឿង នាយករងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)

☺ កំពស់រងអាចលើកចាប់ពី១៥ទៅ៣០សង់ទីម៉ែត្រ ដោយទៅតាមរដូវកាលផងដែរ។

☺ ជាទូទៅដំណាំល្ពៅគេកាប់រណ្ដៅដាំ នៅពេលវាដុះហើយទើបគេពូនរង។

## ៤.ការដាំដុះ

- ជាដំបូងត្រូវលាងសំអាតគ្រាប់ពូជជាមុនសិន រួចយកវាទៅហាលថ្ងៃរយៈពេល៣ម៉ោង។
- យកគ្រាប់ពូជទៅត្រាំទឹករយៈពេល៤ទៅ៥ម៉ោង រួចផ្អាប់១យប់។
- កាប់រណ្ដៅទំហំ២ទៅ៣តឹក ជម្រៅ២ទៅ៣តឹកដែរ។
- គម្លាតរណ្ដៅពីគុម្ពមួយទៅគុម្ពមួយប្រវែង១២០ទៅ១៥០សង់ទីម៉ែត្រ រីឯទ្រូងចាប់ពី២ទៅ៣ម៉ែត្រ។
- ត្រូវដាក់ជីធម្មជាតិឬជីកំប៉ុស្តិ៍សម្រាប់ទ្រាប់បាតរណ្ដៅផង។
- ដាក់គ្រាប់ដាំចំនួន៣ទៅ៤គ្រាប់សម្រាប់១រណ្ដៅដោយកប់ជម្រៅ៣សង់ទីម៉ែត្រ។
- ក្នុងផ្ទៃដី១ហិចតាគេដាំចំនួន៤៥៦៥រណ្ដៅស្មើនឹងចំនួនគ្រាប់៤,៥គីឡូក្រាម។

## ៥.ការជ្រោយដី

- ការជ្រោយដី ពូនគល់ បោចស្មៅ គឺត្រូវធ្វើឡើងក្រោយពីដាំដុះបានរយៈពេល១៥ទៅ២០ថ្ងៃ។
- ត្រូវពិនិត្យនិងដករំលោះកូនចោលខ្លះបើមានកូនច្រើនពេក។

## ៦.ការថែទាំ

- ត្រូវពិនិត្យមើលសត្វល្អិត ឬជម្ងឺផ្សេងៗ។
- ត្រូវស្រោចទឹកឱ្យបានគ្រប់គ្រាន់ចាប់ពីពេលដាំរហូតដល់ពេលប្រមូលផល។

## ៧.ការប្រមូលផល

- ការប្រមូលផលវាអាស្រ័យទៅលើពូជ ពូជខ្លះចាប់ពីអាយុ៨០ទៅ៨៥ថ្ងៃ ពូជខ្លះទៀតចាប់ពីអាយុ៩៥ទៅ១១០ថ្ងៃ។
- ត្រូវពិនិត្យតម្រូវការទីផ្សារ

## ៨.ការរក្សាពូជ

- យើងអាចរក្សាពូជទុកដាំបន្តបានលុះត្រាតែពូជនោះមិនមែនជាពូជបង្កាត់។

រៀបចំដោយ លោក យុគ សឿង នាយករងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)

✓ ត្រូវពិនិត្យយកផ្លែណាដែលទុំល្អ ហើយមិនមានស្នាមសត្វចោះ។

✓ ទុកផ្លែល្ពៅឱ្យទុំញោ រួចទើបពុះយកគ្រាប់ បន្ទាប់មកលាងទឹកវាឱ្យស្អាតល្អ។

✓ យកគ្រាប់ដែលលាងទឹករួចនោះយកទៅហាលថ្ងៃឱ្យស្ងួត រួចហើយច្រកដាក់ក្នុងដប កែវ ឬខ្ចប់នឹងក្រណាត់រក្សាទុកឱ្យបានល្អ៕

**សូមអរគុណ**